## ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ២០១៣

## ជប៉ុនផ្តល់ ២១៣,៩៦២ ដុល្លារអាមេរិក សម្រាប់គម្រោងកែលម្អប្រព័ន្ធលូ ក្នុងខេត្តបាត់ដំបង និងសាងសង់កំពង់ផែក្នុងខេត្តព្រះវិហារ



ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន (ជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ - ជំនួយគូសាណូណេ) រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន២១៣,៩៦២ ដុល្លាអាមេរិក ដល់មន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តបាត់ដំបង និងក្រុមប្រឹក្សាឃុំកំពង់ស្រឡៅ១ ស្រុកឆែប ខេត្តព្រះវិហារ។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខានៅថ្ងៃនេះដោយឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជានិងតំណាងស្ថាប័នទទួលជំនួយទាំង២សម្រាប់អនុវត្តគម្រោងដូចតទៅ៖

<u>១. គម្រោងកែលម្អប្រព័ន្ធលូតាមបណ្តោយផ្លូវជាតិលេខ៥ក្នុងខេត្តបាត់ដំបង (១០៦,៤១៧ដុល្លាអាមេរិក)</u>

<u>ស្ថាប័នទទួលជំនួយ៖ មន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តបាត់ដំបង</u>




ទឹកជំនន់ក្នុងរដូវភ្លៀង (ខេត្តបាត់ដំបង)

គម្រោងនេះគឺដើម្បីសាងសង់ប្រព័ន្ធលូរំដោះទឹកប្រវែង១,០៧០ម៉ែត្រ ដែលមានវិហ្គា៤០តាមបណ្តោយផ្លូវជាតិលេខ៥ ជិតរង្វង់មូលព្រះនារាយណ៍ក្នុងខេត្តបាត់ដំបង។ យើងសង្ឃឹមថា គម្រោងនេះនឹងបង្កើនសមត្ថភាពគ្រប់គ្រងទឹកជំនន់ ព្រមទាំងកែលម្អបរិស្ថានឲ្យមានសុវត្ថិភាព និង អនាម័យ សម្រាប់ប្រជាជនក្នុងតំបន់ ប្រមាណ១៨,០០០នាក់ ។

<u>២. គម្រោងសាងសង់កំពង់ផកំពង់ស្រឡៅ១ ខេត្តព្រះវិហារ (១០៧,៥៤៥ដុល្លាអាមេរិក)</u>

<u>ស្ថាប័នទទួលជំនួយ៖ ក្រុមប្រឹក្សាឃុំកំពង់ស្រឡៅ១ ស្រុកឆែប ខេត្តព្រះវិហារ</u>



ដធម្មជាតិ (ខេត្តព្រះវិហារ)

គម្រោងនេះគឺដើម្បីសាងសង់កំពង់ផថ្មីមួយ និងផែបណ្តែតទឹកនៅលើដងទន្លេមេគង្គដែលចាំបាច់សម្រាប់ជីវភាពប្រចាំថ្ងៃរបស់ប្រជាជនដែលរស់នៅតាមបណ្តោយព្រំប្រទល់ជាមួយប្រទេសឡាវ។ យើងសង្ឃឹមថា គម្រោងនេះនឹងផ្តល់ផលប្រយោជន៍ដល់ប្រជាជនជាង ៥,០០០ នាក់ក្នុងភូមិចំនួន៨នៃតំបន់នោះដែលត្រូវការធ្វើដំណើរឆ្លងកាត់ទន្លេ។ យើងក៏រំពឹងផងដែរថាកំពង់ផថ្មីនេះនឹងរួមចំណែកលើកស្ទួយសេដ្ឋកិច្ចក្នុងតំបន់តាមរយៈការបង្កើនពាណិជ្ជកម្មជាមួយប្រទេសឡាវ។

ជាមួយនឹងជំនួយបច្ចេកទេសពីក្រសួងសាធារណៈការនិងដឹកជញ្ជូនប្រជាសហគមន៍ក្នុងតំបន់គោលដៅទាំងពីរនឹងថែទាំសមិទ្ធផលទាំងនេះឲ្យបានល្អប្រសើរ។

ជំនួយ *គូសាណូណិ* របស់រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍ និងស្តាបនាប្រទេសឡើងវិញនៅតាមកំរិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និងភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជិវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង៥០.៥ លានដុល្លាអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន៥០៥គម្រោងនៅទូទាំងប្រទេស។



---


*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរស័ព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*

*អ៊ីមែល: eco.jpn@.pp.mofa.go.jp*

*គេហទំព័រ: http://www.kh.emb-japan.go.jp*